# ការបង្កើតឡូត៍ពិសោធន៍ដាំជ្រើសរើសប្រភេទឈើចំនួន ២១ប្រភេទ

## នៅក្នុងតំបន់ទីជំរាលក្បាលឆាយ ក្រុងព្រះសីហនុ

ដោយ : ម៉ុយ រដ្ឋា

-មន្ត្រីការិយាល័យដាំឈើ

-មន្ត្រីគំរោងគ្រាប់ពូជឈើកម្ពុជា

## ១. សេចក្តីផ្តើម

### ១.១ លក្ខណៈទូទៅ (Background)

ទីជំរាលក្បាលឆាយស្ថិតនៅក្នុងតំបន់ដីគោកនៃក្រុងព្រះសីហនុ មានសណ្ឋានជាខ្ពង់រាបបាតខ្ពះ មានព្រៃប្រទល់ជាជួរភ្នំតូចៗជាច្រើន ដែលមានផ្ទៃដីទំហំ ៦.២០២ ហ.ត និង មានរយៈកំពស់ប្រហែល ១០០-២០០ម៉ែត្រ ធៀបទៅនឹងសមុទ្រ។ ទីនេះ ត្រូវបានគេគិតទុកថាជាប្រភពទឹកសំរាប់ផ្គត់ផ្គង់ក្រុងព្រះសីហនុ ទៅថ្ងៃអនាគត។ ការកាប់ឈើ និង ការរំលោភយកដីដ៏ធ្ងន់ធ្ងរនាំឱ្យមានការគំរាមកំហែងយ៉ាងខ្លាំងក្លា ចំពោះធនធានធម្មជាតិនៅតំបន់ក្បាលឆាយ។ ដើម្បីស្រោចស្រង់សភាពការណ៏នៅឆ្នាំ ១៩៩៧ រាជរដ្ឋាភិបាលបានចេញអនុក្រិតលេខ ៧៦ អនក្រ.បក ដែលបានចែងថា “ក្បាលឆាយត្រូវបានចាត់ទុកជាតំបន់បំរុងទុកសំរាប់ផលប្រយោជន៏សាធារណៈ ” ក្នុងគោលបំណងការពារ និង ស្តារតំបន់នេះ ឡើងវិញ (KCWP, 2004)។



ទិដ្ឋភាពទូទៅនៃឡូត៍ពិសោធន៍

### ១.២ ហេតុនៃការសិក្សា (Rationale of study)

ហេតុដែលយើងជ្រើសរើសប្រធានបទស្តីពី ការបង្កើតឡូត៏ពិសោធន៏ដាំជ្រើសរើសប្រភេទឈើ នៅក្នុងតំបន់ក្បាលឆាយ យកមកសិក្សានៅពេលនេះ ព្រោះតំបន់នោះ មានកម្មវិធីដាំឈើជាទ្រង់ទ្រាយធំប្រចាំឆ្នាំ ហើយការសិក្សាស្វែងយល់ពីការលូតលាស់របស់ប្រភេទឈើនីមួយៗ មិនទាន់បានធ្វើនៅឡើយ។ លទ្ធផលពីឡូត៏ពិសោធន៏នឹងបានជាពត៌មានដ៏សំខាន់ដល់បណ្តាអ្នកដាំឈើទាំងឡាយយកមកអនុវត្តនៅពេលអនាគត ក្នុងការងារដាំឈើលើតំបន់ទីជំរាលក្បាលឆាយ នៃក្រុងព្រះសីហនុ។

### ១.៣ គោលបំណង (Objectives)

គោលបំណងនៃការបង្កើតឡូត៏ពិសោធន៏ដាំជ្រើសរើសប្រភេទឈើ គឺជាការប្រៀបធៀបក្នុងគ្រោងការដាំសាកល្បងយ៉ាងហ្មត់ចត់មួយ នូវប្រភេទពូជជំរើសត្រូវបានដាំនៅក្នុងបរិស្ថានពីរប្រភេទ ឬ ច្រើន ដើម្បីសិក្សាតើពូជមួយណាដុះកបបំផុតនៅទីចំការណាមួយ។ គេប្រើវិធីសាកល្បងនេះ ជាមុនទើបនាំចូលប្រភេទពូជថ្មីមកដាំនៅតំបន់ណាមួយ ហើយធ្វើមុន រឺ ធ្វើគួបផ្សំការដាំសាកល្បងប្រភពកំណើត(CTSP,2004)។

# ២. សម្ភារះនិងវិធីសាស្ត្រ (Materials and methods)

## ២.១ ទីតាំងធ្វើពិសោធន៍ (Experimental site)

ការពិសោធន៍ត្រូវបានបង្កើតឡើងនៅ ខែមិថុនា ឆ្នាំ២០០៤ នៅក្នុងតំបន់ទីជំរាលក្បាលឆាយ នៃក្រុងព្រះសីហនុ ដែលមានចំងាយប្រហែល ៣គម ពីផ្លូវជាតិលេខបួន និង ១គម ខាងក្រោយរោងចក្រកាត់ដេ Growntech ។ ទីជំរាលក្បាលឆាយមានសីតុណ្ហភាពប្រចាំថ្ងៃចន្លោះពី ២៤-៣២°C និង មានរដូវប្រាំងចាប់ផ្តើមពីខែ វិច្ឆិកា រហូតដល់ខែ មេសា ។ ក្រុងព្រះសីហនុ ស្ថិតនៅប៉ែកនិរតីនៃប្រទេសកម្ពុជា បើយើងធ្វើដំណើរពីភ្នំពេញតាមផ្លូវជាតិលេខ ៤ មានចំងាយ ២៣០ គម ពីរាជធានីភ្នំពេញ។

## ២.២ វិធីសាស្ត្រពិសោធន៍ (Experimental methods)

- រៀបចំប្លង់ពិសោធន៍មានរាងចតុកោណកែង ដើម្បីអោយកូនឈើនៅជុំគ្នាងាយស្រួលគ្រប់គ្រងថែរក្សា និងជាតំណាងអោយផ្ទៃដីដាំឈើទៅអនាគត។
- ផ្ទៃដីទាំងមូលត្រូវបានភ្ជួររាស់ដោយត្រាក់ទ័រ មុនពេលធ្វើការដាំដុះកូនឈើ។
- ទាញខ្សែវាយចេ្បាះ និង កាប់រណ្តៅដាំកូនឈើទំហំ 3dm x 3dm និង ជំរៅ 2-3dm ។
- ដើម្បីការពារឡូត៍ពិសោធន៍ពីភ្លើងឆេះនៅក្នុងរដូវប្រាំង យើងត្រូវភ្ជួររាស់ដីកំចាត់ស្មៅមួយដងក្នុងមួយឆ្នាំ។
- ធ្វើផ្លូវការពារភ្លើងព័ទ្ធជុំវិញចំការឈើ ដោយជំរះសំអាតស្បូវ ឬ ស្មៅ ជាប្រឡោះទំហំ ៥ម ហើយត្រូវឆ្ការសំអាតផ្លូវភ្លើងនេះនៅដើមរដូវប្រាំង និង ប្រមូលសំរាមចេញអោយឆ្ងាយ ឬ ដុតចោលយ៉ាងប្រុងប្រយ័ត្ន។



ការៀបចំប្រភេទកូនឈើសំរាប់ដាំតាមសារ




ផ្លាកសញ្ញាប្រភេទឈើនីមួយៗ

### ប្រភេទឈើប្រើជាបច្ច័យសំរាប់ពិសោធន៍

| ល.រ | ប្រភេទឈើ | | បរិមាណ | ប្រភពកូនឈើ | | |
|---|---|---|---|---|---|---|
| | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះខ្មែរ | | ក្បាលឆាយ | បែកចាន | បាក់ស្នា |
| 1 | *Afzelia xylocarpa* | បេង | 105 | 105 | 0 | 0 |
| 2 | *Aquilaria crassna* | ចន្ទន៍ក្រស្នា | 105 | 105 | 0 | 0 |
| 3 | *Archidendron quocense* | អង្គញ់ស្វា | 105 | 105 | 0 | 0 |
| 4 | *Azadirachta indica* | ស្ដៅ | 105 | 105 | 0 | 0 |
| 5 | *Cassia fistula* | ល្មឿងរាជ | 105 | 105 | 0 | 0 |
| 6 | *Cassia siamea* | អង្កាញ់ | 105 | 105 | 0 | 0 |
| 7 | *Dalbergia bariensis* | នាងនួន | 105 | 0 | 0 | 105 |
| 8 | *Dalbergia cochinchinensis* | ក្រញូង | 105 | 0 | 0 | 105 |
| 9 | *Dipterocarpus alatus* | ឈើទាលទឹក | 105 | 105 | 0 | 0 |
| 10 | *Dipterocarpus retusus* | ឈើទាលប្រេង | 105 | 105 | 0 | 0 |
| 11 | *Hopea recopei* | ពពេល | 105 | 0 | 105 | 0 |
| 12 | *Hopea odorata* | គគីរម្សៅ | 105 | 105 | 0 | 0 |
| 13 | *Irvingia malayana* | ចំបក់ | 105 | 105 | 0 | 0 |
| 14 | *Khaya senegalensis* | គ្រាប់បែក | 105 | 0 | 105 | 0 |
| 15 | *Leucaena leucocephala* | ក្រទុំថេត | 105 | 105 | 0 | 0 |
| 16 | *Peltophorum dasyrrhachis* | ត្របែក | 105 | 105 | 0 | 0 |
| 17 | *Pterocarpus macrocarpus* | ធ្នង់ | 105 | 105 | 0 | 0 |
| 18 | *Shorea guiso* | ជ័រចុង | 105 | 105 | 0 | 0 |
| 19 | *Sterculia lychnophora* | សំរ៉ង | 105 | 105 | 0 | 0 |
| 20 | *Syzygium cumini* | ព្រីង | 105 | 105 | 0 | 0 |
| 21 | *Tarrietia javanica* | ដូនចែម | 105 | 105 | 0 | 0 |

* **ឈ្មោះវិទ្យាសាស្ត្រ ( ឌី ផុន ប៉ូលីន , ២០០០ )**

### ២.៣ ប្លង់ពិសោធន៍ (Experimental design)

- ប្លង់ពិសោធន៍ Randomized Complete Block Design (RCBD) ដែលមាន ៤សារ (Replications) និង មួយសារមាន ២១បច្ច័យ (Treatments) ឬ ២១ប្រភេទ ហើយក្នុងមួយបច្ច័យមានកូនឈើ ២៥ដើម សរុបកូនឈើទាំងបួនសារមានចំនួន ២.១០០ដើម ។
- ប្លង់ពិសោធន៍ទំហំ : ៣០០ម x ៥០ម = ១,៥ ហ.ត
- ដាំកូនឈើក្នុងគំលាត : ២ម x ៣ម

## ២.៤ ការប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យ គឺធ្វើឡើងក្រោយពេលកូនឈើត្រូវបានដាំរួចរយៈពេល ១ខែ និង ធ្វើការដាំជួសរួចរាល់ ហើយស្រង់ទិន្នន័យនៅរយៈពេល ៦ខែម្តង និង ជាបន្តរយៈពេល ១ឆ្នាំម្តង ជារៀងរាល់ឆ្នាំ។ ការវាស់កំពស់ អង្កត់ផ្ចិត និង អត្រារស់នៃកូនឈើត្រូវបានធ្វើទៅតាមបច្ច័យ និង សារ។ ការវាស់វែងធ្វើឡើងតាមលំដាប់លេខរៀងកូនឈើនៅក្នុងបច្ច័យ (មើលប្លង់ពិសោធន៍)។

ខ្នាតសំរាប់វាស់កំពស់កូនឈើគិតជាសង់ទីម៉ែត្រ អង្កត់ផ្ចិតគិតជាមីលីម៉ែត្រ និង អត្រារស់របស់កូនឈើគិតជាភាគរយ។ ការវាស់កំពស់ត្រូវបានវាស់តួដើមត្រង់ចំណុចគល់កូនឈើពីដី ដល់ចំណុចខ្ពស់បំផុតនៃដើម។ ចំពោះអង្កត់ផ្ចិតត្រូវបានវាស់ត្រង់ចំណុចគល់កូនឈើនៅកំពស់ 2cm ពីដី ។



សកម្មភាពចុះវាស់វែងកូនឈើរយៈពេល ១ឆ្នាំ



ឧបករណ៍វាស់អង្កត់ផ្ចិតកូនឈើ

# ប្លង់ពិសោធន៍ជាំជ្រើសរើសប្រភេទឈើចំនួន ២១ប្រភេទ

## Randomized Complete Block Design (RCBD)



## ៣. លទ្ធផលនៃការដាំជ្រើសរើសប្រភេទឈើក្នុងរយៈពេល ១២ខែ

តាមក្រាហ្វិកទី ១ , ២ និង ៣ បានបង្ហាញនូវកំណើនលូតលាស់កំពស់ , អង្កត់ផ្ចិត និង អត្រារស់ នៃកូនឈើក្នុងស្រុកទាំង ២១ប្រភេទ ដូចខាងក្រោម :




**ក្រាហ្វិកទី ១ : កំពស់មធ្យមរបស់កូនឈើនៅពេលដាំ និង រយៈពេល ១២ខែ**

ការលូតលាស់កំពស់កូនឈើទាំង ២១ប្រភេទ ក្នុងដំណាក់កាលដំបូងបានបង្ហាញឱ្យឃើញថា មានប្រភេទឈើចំនួន ៥ប្រភេទ លូតលាស់លឿន ( **លឿងរាជ, អង្កាញ់, ពពេល, គ្រាប់បែក, សរ៉ែង** ) និង ៤ប្រភេទ លូតលាស់មធ្យម ( ចន្ទន៍ក្រស្នា , អង្គញ់ស្វា , ក្រញូង , ត្រសេក ) និង ៧ប្រភេទ ផ្សេងទៀតលូតលាស់យឺត ( នាងនួន , ឈើទាលទឹក , គគីរម្សៅ , ចំបក់ , ធ្នង់ , ព្រីង និង ដូនចែម ) ហើយប្រភេទឈើក្រៅពីនេះ ច្រើនស្ថិតស្រពោនបាក់ចុងនៅក្នុងរដូវប្រាំងដែលអូសបន្លាយពេលយូរដូចជា : បេង , ស្តៅ , ឈើទាលប្រេង , ក្រទុំថេត និង ជ័រចុង ។




គ្រាហ្វិកទី ២ : អង្កត់ផ្ចិតមធ្យមរបស់កូនឈើនៅពេលដាំ និង រយៈពេល ១២ខែ

តាមក្រាហ្វិកទី ២ បានបង្ហាញអោយឃើញថា មានកូនឈើចំនួន ៦ប្រភេទ ( លឿងរាជ , អង្កាញ់ , ក្រញូង , ពពេល , គ្រាប់បែក និង ត្រសេក ) ដែលមានអង្កត់ផ្ចិតលូតលាស់លឿននៅក្នុងដំណាក់កាល ១២ខែដំបូង និង ប្រភេទឈើចំនួន ៧ប្រភេទទៀត លូតលាស់មធ្យម (ចន្ទន៍ក្រស្នា , អង្គញ់ស្វា , គគីរម្សៅ , ចំបក់ , ធ្នង់ , សរ៉ែង និង ព្រីង) ហើយប្រភេទឈើក្រៅពីនេះ មានអង្កត់ផ្ចិតលូតលាស់យឺតនៅក្នុងដំណាក់កាលដំបូងដូចជា : បេង , ស្តៅ , នាងនួន , ឈើទាលទឹក ,ឈើទាលប្រេង, ក្រទុំថេត , ជ័រចុង និង ដូនចែម ។




## ក្រាហ្វិកទី ៣ : អត្រារស់របស់កូនឈើទាំង ២១ប្រភេទ

តាមក្រាហ្វិករយៈពេល ៦ខែដំបូង ( មិថុនា-ធ្នូ/២០០៤) បានបង្ហាញឱ្យឃើញថា ការពិសោធន៍ដាំជ្រើសរើសប្រភេទឈើមានអត្រារស់ល្អជាទូទៅនៅចន្លោះពី ៧៨%-១០០% ។ ប៉ុន្តែប្រភេទឈើមួយចំនួនមានអត្រារស់ធ្លាក់ចុះដូចជា ព្រីង( ៨៩%) , ចន្ទន៍ក្រស្នា( ៨៦%), ជ័រចុង( ៨៣%), អង្គញ់ស្វា( ៧៨%) និង សំរ៉ង( ៧៨%) ហើយប្រភេទឈើក្រៅពីនេះ មានអត្រារស់ខ្ពស់ពី ៩២%-១០០% ។

អត្រារស់ក្នុងរយៈពេល ១២ខែបន្ទាប់ ( មិថុនា/២០០៤-មិថុនា/២០០៥) យើងសង្កេតឃើញថាមានការប្រែប្រួលខ្លាំង បើប្រៀបធៀបទៅនឹងរយៈពេល ៦ខែដំបូង។ ព្រោះក្នុងដំណាក់កាលនេះ កូនឈើឆ្លងកាត់រដូវប្រាំង ដែលកូនឈើមួយចំនួនមិនអាចធនទ្រាំភាពរាំងស្ងួត។ តាមក្រាហ្វិកឃើញថាមានប្រភេទឈើចំនួន៤ មានអត្រារស់ ១០០% **( ក្រញូង , ពពេល , គ្រាប់បែក និង ផ្ចង់ )** និង ប្រភេទឈើចំនួន ៩ប្រភេទទៀត មានអត្រារស់ល្អ បេង ( ៩៤%), ស្ពៅ( ៩៧%), លឿងរាជ( ៩៤%), អង្កាញ់( ៧៨%), នាងនួន( ៩២%), គគីរម្សៅ( ៩៧%),ចំបក់( ៩២%), ត្រសេក ( ៩៧%) និង ដូនថែម( ៨៦%)។ កូនឈើចំនួន ៦ប្រភេទផ្សេងទៀត មានអត្រារស់ធ្លាក់ចុះចន្លោះពី ៥៣%-៦៩% ( ចន្ទន៍ក្រស្នា , ឈើទាលទឹក , ឈើទាលប្រេង , ក្រទុំថេត , ជ័រចុង និង ព្រីង ) ហើយមានកូនឈើពីរប្រភេទ ដែលអត្រារស់ទាបបំផុតគឺ អង្គញ់ស្វា( ១៧%) និង សំរ៉ង( ២៥%) ។

## ៤. សន្និដ្ឋាននិងអនុសាសន៍

ឆ្លងតាមការពិសោធន៍រយៈពេល ១ឆ្នាំ យើងសង្កេតឃើញប្រភេទឈើជាទូទៅមានអត្រារស់ខ្ពស់ តែប្រភេទមួយចំនួនមិនអាចធន់ទ្រាំភាពរាំងស្ងួត ដែលអូសបន្លាយពេលក្នុងរដូវប្រាំង ជាហេតុបណ្តាលឱ្យកូនឈើត្រូវងាប់ច្រើន ដូចជា អង្គញ់ស្វា(១៧%) , សរ៉ាំង(២៥%) , ជ័រចុង(៩៣%) និង ចន្ទន៍ក្រស្នា(៥៦%) ។

ប្រសិនបើគិតដល់លទ្ធផលដំបូងពីការលូតលាស់កំពស់ អង្កត់ផ្ចិត និង អត្រារស់ នៃការដាំជ្រើសរើសប្រភេទឈើទាំង ២១ ក្នុងតំបន់ក្បាលឆាយ ក្រុងព្រះសីហនុ ប្រភេទឈើលឿងរាជ អង្កាញ់ ក្រញូង ពពេល គ្រាប់បែក និង ត្រសេក អាចត្រូវបានផ្តល់ជាអនុសាសន៍សំរាប់ធ្វើការដាំដុះក្នុងតំបន់ទីជំរាលក្បាលឆាយ ប្រភេទនេះផ្តល់ការលូតលាស់ឆាប់រហ័ស និង មានអត្រារស់ខ្ពស់ បើប្រៀបធៀបក្នុងចំណោមប្រភេទឈើផ្សេងៗ។ម្យ៉ាងវិញទៀត ប្រសិនបើកូនឈើប្រភេទខាងលើមិនអាចរកបាន យើងអាចប្រើប្រាស់ប្រភេទឈើបន្ទាប់មកជំនួសដូចជា ចន្ទន៍ក្រស្នា , នាងនួន, ឈើទាលទឹក , គគីរម្សៅ , ចំបក់ , ធ្នង់ , ព្រីង និង ដូនចែម ។

ការសិក្សានេះ ទោះជាមានចំណុចខ្វះខាតមួយចំនួនដូចជា កូនឈើយកមកពិសោធន៍មានអាយុមិនស្មើគ្នា តែយើងរកបានកូនឈើច្រើនប្រភេទ យកមកសាកល្បងពិសោធន៍ដាំជ្រើសរើសប្រភេទឈើ។លទ្ធផលជំហានដំបូងនេះពុំទាន់ទទួលយកជាផ្លូវការបាននៅឡើយ ព្រោះត្រូវរង់ចាំវិភាគលទ្ធផលនៅឆ្នាំបន្តបន្ទាប់ទៀត។

**ឯកសារយោង :**


- ឌី ផុន ប៉ូលីន , ២០០០ *រុក្ខជាតិប្រើប្រាស់ក្នុងប្រទេសកម្ពុជា* , ភ្នំពេញ , កម្ពុជា ។
- Cambodia Tree Seed Project (CTSP). 2004. *Glossary of Seed Biology and Tree Improvement English-Khmer.* Institutional Capacity Building of the Tree Seed Sector. Forestry Administration. Phnom Penh, Cambodia.
- Kbal Chhay Watershed Project (KCWP), 2004.